Annex 2

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

កម្មវិធីសីលា

គំរោងគ្រប់គ្រងធនធានធម្មជាតិ
ដោយសហគមន៍

# លក្ខន្តិកៈ

## សហគមន៍គ្រប់គ្រងធនធានធម្មជាតិល្អឺនក្រែន



ឧបត្ថម្ភគាំទ្រដោយអង្គការ IDRC/CARERE តាមរយៈ

កម្មវិធីសីលា ខេត្តរតនគីរី

library.ncdd.gov.kh
007337

០១ មករា ២០០១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បណ្ណាល័យ
គ.ជ.អ.ប

# កិច្ចព្រមព្រៀង

- យោងកំណត់ហេតុស្តីពីការពិភាក្សាអំពីព្រំប្រទល់តំបន់ប្រើប្រាស់ភូមិល្បឺនក្រែន ជាមួយភូមិ ឃុំជិតខាងកាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩។
- សិក្ខាសាលា កែសំរួលសេចក្តីព្រាងលក្ខន្តិកៈគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ថ្នាក់ស្រុកកាលពីថ្ងៃទី២៩-៣០ ខែ សីហា ឆ្នាំ ២០០០។
- កិច្ចប្រជុំកែសំរួលសេចក្តីព្រាងលក្ខន្តិកៈសហគមន៍គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ជាមួយមន្ត្រីជំនាញថ្នាក់ខេត្ត ថ្ងៃទី ២៨ ខែ វិច្ឆកា ឆ្នាំ ២០០០។

ខាងក្រោមនេះគឺជាកិច្ចសន្យារវាងភាគី(ក)គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តរតនៈគីរីដែលរួមមានមន្ទីរជំនាញនានា ជាសេនាធិការ និងភាគី(ខ)គណៈកម្មាការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ។

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តរតនៈគីរី បានយល់ព្រមចុះកិច្ចសន្យាប្រគល់ការគ្រប់គ្រងធនធានធម្មជាតិទៅអោយគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ក្រោមកិច្ចព្រមព្រៀងនិងលក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោម:

១. គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ត្រូវមានភារៈកិច្ចដឹកនាំសហគមន៍លើការទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងចាត់ចែង ថែរក្សាការពារ និងអភិវឌ្ឍន៍នៅក្នុងតំបន់គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែនដូចមានចែងនៅក្នុងលក្ខន្តិកៈគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន។

២. តំបន់គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែនដែលចុះកិច្ចសន្យាព្រមព្រៀងជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តដែលបានកំនត់ដោយផែនទីដូចភ្ជាប់មកជាមួយ និងមានទំហំ ៩០៦ហិកតា (ប្រាំបួនរយសូន្យប្រាំមួយហិកតា) ដែលចែកចេញជា ២តំបន់ប្រើប្រាស់ដាច់ពីគ្នាដូចមានចែងនៅក្នុងលក្ខន្តិកៈគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន។

៣. គណៈកម្មការការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន គឺជាភ្នាក់ងារចំបងក្នុងការអនុវត្តន៍ ទំនាក់ទំនងរៀបចំផែនការ សរសេររបាយការណ៍ រាយការណ៍ជូនមកគណៈកម្មាធិការអភិវឌ្ឍន៍ឃុំ ស្រុក ស្ថាប័នជំនាញ



333.72
STA
sh: Natural Res

លេខ: 017/2001

បានឃើញនិង ឯកភាព

ថ្ងៃទី.....ខែ..........ឆ្នាំ ២០០០

ប្រធានមន្ទីរបរិស្ថានខេត្ត

ហោ_ហុង

លេខ:..........................................

បានឃើញនិង ឯកភាព

ថ្ងៃទី 23 ខែ 01 ឆ្នាំ ២០០៨

អភិបាលស្រុកអូរជុំ

ប៉ឿន_ធឿន

លេខ: 27 កសិខ

បានឃើញនិង គាំទ្រ

..........ថ្ងៃទី 23 ខែ 01 ......ឆ្នាំ២០០០

ប្រធានមន្ទីរកសិកម្មរុក្ខា.ប្រមាញ់ និងនេសាទខេត្ត

ប្រធាន

ឌិន.សុខុន

លេខ: 11 ៥ ភ.ស.ស.

បានឃើញនិង ឯកភាព

..........ថ្ងៃទី 28 ខែ 01 .....ឆ្នាំ២០០៨

ប្រធានមន្ទីររៀបចំដែនដី នគររូបណីយកម្ម សំណង់ និងសុរិយោដីខេត

ប្រធាន

ហែន_បាគគង់

លេខ: 048/2001

បានឃើញនិង..........................................

..............ថ្ងៃទី 29 ខែ 01 ឆ្នាំ២០០០

ឯកឧត្តមអភិបាល និងជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តរតនគីរី

ខាំ_ខឿន

# សមាជិកគណៈកម្មការគ្រប់គ្រងធនធាន ធម្មជាតិល្បើនក្រែន

| ល.រ | នាម និងគោត្តនាម | ភេទ | តួនាទី |
|---|---|---|---|
| ០១ | លោក គិះ ជួន | ប្រុស | ក្រុមស្តួលសហគមន៍ឃុំអូរជុំ ជាទីប្រឹក្សា |
| ០២ | លោកស្រី ភីង បង់ | ស្រី | ក្រុមស្តួលសហគមន៍ឃុំអូរជុំ ជាទីប្រឹក្សា |
| ០៣ | លោក កាំង ណាវ | ប្រុស | ចាស់ទុំភូមិ ជាទីប្រឹក្សា |
| ០៤ | លោក ញ៉ឹល បូប | ប្រុស | ប្រធានគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ |
| ០៥ | លោក ព្យង វិន | ប្រុស | អនុប្រធានគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ |
| ០៦ | លោក ផាយ យឿន | ប្រុស | ផ្នែកអប់រំផ្សព្វផ្សាយ |
| ០៧ | លោក ព្រួយ លី | ប្រុស | ផ្នែកល្បាត |
| ០៨ | លោកស្រី រមាំង អិន | ស្រី | ផ្នែកបេឡា |
| ០៩ | លោក និង យន | ប្រុស | ក្រុមល្បាតទី១ |
| ១០ | លោក ហើយ កិត | ប្រុស | ក្រុមល្បាតទី២ |
| ១១ | លោក លិក គ | ប្រុស | ក្រុមល្បាតទី៣ |
| ១២ | លោក ទុន នី | ប្រុស | ក្រុមល្បាតទី៤ |
| ១៣ | លោក កើត ធិន | ប្រុស | ក្រុមល្បាតទី៥ |


ផែនទីប្រើប្រាស់ដីភូមិល្អឺនក្រែន
N
សញ្ញាសម្គាល់
អូរ:
បឹង
ដីប្រើប្រាស់:
0
500 Meters

# សេចក្តីព្រាងលក្ខន្តិកៈសហគមន៍គ្រប់គ្រង ធនធានធម្មជាតិល្អឺនក្រែន

ល្អឺនក្រែន គឺជាភូមិមួយក្នុងចំណោមភូមិទាំង ៨ ស្ថិតក្នុងឃុំអូរជុំ ស្រុកអូរជុំ ដែលមានប្រជាពលរដ្ឋ ៣៥៦នាក់ ស្រី ១៩២ នាក់ ស្មើនិង ៨៨គ្រួសារ ជនជាតិ ទំពួន រស់នៅពឹងផ្អែកទាំងស្រុងទៅលើធនធានធម្មជាតិ និងការធ្វើកសិកម្មពិវិលជុំ ដែលក្នុងនោះមានផ្ទៃដីប្រើ ប្រាស់ភូមិសរុប ៩០៦ហិកតា ដែលមានព្រំប្រទល់:

- ខាងត្បូងជាប់នឹងភូមិល្អឺនជង (តាមបណ្តោយអូរតាពាល)។
- ខាងជើងជាប់នឹងផ្លូវជាតិលេខ ៧៨(តាមបណ្តោយផ្លូវជាតិ)។
- ខាងកើតជាប់នឹងភូមិប៉ាជន់ (ភ្នំកាឡាច់)។
- ខាងលិចជាប់នឹងភូមិភ្នំ និងភូមិអូរជុំ(តាមបណ្តោយអូរកាជូច)។ដោយចែកចេញជាតំបន់ប្រើប្រាស់និងគ្រប់គ្រងពីរដាច់ពីគ្នាដូចជា:

### ១.តំបន់ព្រៃការពារ ៧១ ហិកតា ចែកចេញជាតំបន់ដូចខាងក្រោម :

- ព្រៃឫស្សីផ្អេរ និងពក ចំនួន ២១ហិកតា (អូរក្រែនតូច ២ហិកតា ក្រែនធំ ១២ហិកតា និងជើងភ្នំកាឡាច់ ៧ហិកតា) ដុះលើដីក្រហមនៅទីជំរាលជងអូរ និងជើងភ្នំ។
- ព្រៃជុំវិញភូមិ និងព្រៃប្រភពទឹក ២៩ហិកតា (តំបន់ព្រៃចំការចាស់) ដុះនៅលើដីក្រហមតាមទីជំរាលក្បាលអូរ ជាប្រភេទព្រៃដុះថ្មី។
- ព្រៃអារក្ស ២១ហិកតា ជាប្រភេទព្រៃពាក់កណ្តាលស្រោង ដុះលើតំបន់កូនភ្នំ ជាប្រភេទដីព៌ណប្រផេះ គ្រួស និងថ្ម។

### ២.តំបន់ដីប្រើប្រាស់ ៨៣៥ ហិកតា ចែកចេញជាតំបន់ផ្សេងៗគ្នាដូចខាងក្រោម:

- ដីលំនៅដ្ឋាន ១៩ហិកតា (២០ម គុណ ១០០ម ក្នុងមួយគ្រួសារ)។

**ប្រការ ២ ៖ មូលហេតុ**

- កំនើនប្រជាជន(អ្នកខាងក្នុង និងអ្នកខាងក្រៅសហគមន៍)។
- ធនធានធម្មជាតិកាន់តែថយចុះ។
- អ្នកភូមិពុំសូវយល់អំពីសារៈប្រយោជន៍ និងគ្មានផែនការគ្រប់គ្រងច្បាស់លាស់។

## ជំពូក ២

## បទបញ្ញត្តិទូទៅ

**ប្រការ ៣ ៖**

- សហគមន៍នេះមានឈ្មោះថា: **"សហគមន៍គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន" ២**
- សហគមន៍គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ធ្វើការគ្រប់គ្រងលើផ្ទៃដីប្រមាណ ៩០៦ ហិកតា ចែកចេញជាពីរតំបន់ គឺតំបន់ព្រៃការពារ ៧១ហិកតា និងតំបន់ដីប្រើប្រាស់ច្រើនយ៉ាង ៨៣៥ហិកតា។ ក្រោមកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។

**ប្រការ ៤៖**

- សហគមន៍គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ស្ថិតនៅក្រោមការគ្រប់គ្រងមើលការខុសត្រូវផ្ទាល់ពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ លើធនធានធម្មជាតិក្នុងការថែរក្សា ការពារ ដាំដុះ ទាញយកផលតាមលក្ខណៈសមស្រប ដើម្បីឆ្លើយតបទៅនឹងតំរូវការប្រើប្រាស់ប្រចាំថ្ងៃ និងការអភិវឌ្ឍន៍ភូមិ។

**គំនូសបំព្រួញរចនាសម្ព័ន្ធគ្រប់គ្រងធនធានធម្មជាតិល្អឹនក្រែនមានដូចខាងក្រោម:**




**ប្រការ ៨ : តួនាទីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ**

**ក្រុមស្នូលសហគមន៍ :**

- ជាទីប្រឹក្សារបស់គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ ដូចជា: ជួយសំរបសំរួលក្នុងការរៀបចំផែនការ ការទំនាក់ទំនងការងារជាមួយថ្នាក់ឃុំ ស្រុក ខេត្ត និងការត្រួតពិនិត្យ វាយតំលៃ។

- ជួយស្ថាប័នជំនាញក្នុងការផ្សព្វផ្សាយច្បាប់ផ្សេងៗដល់សហគមន៍ក្នុងភូមិ។

## ផ្នែកបេឡា :

- គ្រប់គ្រងរាល់ថវិកា ចំណូល និងចំណាយ។

## ផ្នែកល្បាត :

- តាមដាន រៀបចំកំលាំងដើម្បីចុះពិនិត្យ និងរាយការណ៍មកគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ។
- អនុវត្តសកម្មភាពនានាតាមការស្នើសុំរបស់គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ។

## ក្រុមល្បាតនីមួយ ៥ :

- ទទួលខុសត្រូវតាមដាន ឃ្លាំមើលនៅតាមតំបន់ប្រើប្រាស់នីមួយៗ ឬ តំបន់ដែលខ្លួនរស់នៅ រួចរាយការណ៍មកផ្នែកល្បាត។
- ជួយកិច្ចការផ្សេងៗទៀតតាមការស្នើសុំរបស់ផ្នែកល្បាត ឬ គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ។

## ប្រការ ៩ : សិទ្ធិបោះឆ្នោត

- ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានលំនៅជាអចិន្ត្រៃយ៍នឹងស្របច្បាប់ក្នុងភូមិដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ទើបមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិរបស់ខ្លួនដោយស្ម័គ្រចិត្ត។

## ប្រការ ១០ : សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត

- ប្រជាពលរដ្ឋទាំងពីរភេទដែលមានលំនៅជាអចិន្ត្រៃយ៍នឹងស្របច្បាប់ក្នុងភូមិដែលមានអាយុចាប់ពី ២៥ឆ្នាំឡើង ទើបអាចមានសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោតជាគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ។

### ប្រការ ១១ ៖ អាណត្តិរបស់គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ

- អាណត្តិរបស់គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិមានរយៈពេល ២ ឆ្នាំម្តង ដែលប្រព្រឹត្តទៅនៅខែមករា រៀងរាល់ពីរឆ្នាំម្តង។
- អាណត្តិរបស់គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ អាចធ្វើការផ្លាស់ប្តូរមុនពេលកំណត់បានប្រសិនបើមានការស្នើរសុំពីប្រជាពលរដ្ឋ គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ ដោយមានមូលហេតុច្បាស់លាស់ និងសំរេចដោយការប្រជុំអនុមតិពីអ្នកភូមិ ឬ បោះឆ្នោតជាចំហរ។

### ប្រការ ១២ ៖

- គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ធ្វើការដោះស្រាយទំនាស់ដោយផ្អែកលើលក្ខន្តិកៈ ដោយមានការពិភាក្សាជាមួយសមាជិកគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ ចាស់ទុំភូមិ ឬ ករណីចាំបាច់ត្រូវមានការប្រជុំពិគ្រោះយោបល់ពីប្រជាជនក្នុងភូមិ។ ក្នុងករណីមិនអាចដោះស្រាយបានគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ ធ្វើកំណត់ហេតុនៃការដោះស្រាយមកអាជ្ញាធរឃុំ ស្រុក និងស្ថាប័នជំនាញ។

## ជំពូក ៤

## ការគ្រប់គ្រងហិរញ្ញវត្ថុ

### ប្រការ ១៣ ៖ ថវិកាចំណូល និងចំណាយ

- ថវិកាទាំងអស់ដែលបានមកពីអ្នកទ្រទ្រង់ ការផាកពិន័យ ការដកហូតផលព្រៃឬស្សី ឬ ធនធានផ្សេងៗ នៅក្នុងដែនគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ត្រូវបានរក្សាទុកសំរាប់ដំណើរការ ការពារ ថែរក្សា និងធ្វើការអភិវឌ្ឍន៍ភូមិ។

- រាល់ការចំណាយត្រូវមានការឯកភាពពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ និងអ្នកទ្រទ្រង់ ដោយមានឯកសារគ្រប់គ្រាន់។
- រាល់ការចំណូល និងចំណាយផ្សេងៗប្រចាំខែ ត្រីមាស ត្រូវរាយការណ៍ដល់សមាជិកសហគមន៍ក្នុងភូមិនៅពេលប្រជុំ។

# ជំពូក ៥
## ការប្រើប្រាស់ និងការដកហូត

**ប្រការ ១៤ :**

- សហគមន៍ និងសហគមន៍ជិតខាងអាចទាញយកផលព្រៃឫស្សីតាមបែបប្រពៃណីសមស្រប តែជៀសវៀងការបំផ្លាញ។
- តំបន់ឫស្សីផ្ទរ ពក អាចធ្វើអាជីវកម្មបានតាមលក្ខណៈសមស្រប ដោយមានការពិគ្រោះយោបល់ យល់ព្រមពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ និងមានលិខិតអនុញ្ញាតិដែលចេញពីស្ថាប័នជំនាញ អាជ្ញាធរដែនដី។

**ប្រការ ១៥ :**

- សហគមន៍ និងសហគមន៍ជិតខាងអាចទាញយកអនុផលព្រៃឈើតាមបែបប្រពៃណីសមស្រប តែជៀសវៀងការបំផ្លាញ។

**ប្រការ ១៦ :**

- សហគមន៍ និងសហគមន៍ជិតខាងអាចប្រើប្រាស់ផលព្រៃឈើដូចជា: ឬ្សសខ្មោច គ្រឿងសំណង់បន្ទាប់បន្សំតាមបែបប្រពៃណីសមស្រប លើកលែងតែគ្រឿងសំណង់ធំៗត្រូវមានការពិគ្រោះយោបល់ពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ និងមានលិខិតអនុញ្ញាតិពីស្ថាប័នជំនាញ។

**ប្រការ ១៧ :**

- សហគមន៍ និងសហគមន៍ជិតខាងអាចធ្វើការនេសាទតាមបែបប្រពៃណីសមស្របដូចជាៈ មង តុំ ទ្រូ លាយ សន្ទូច សំណាញ់ ។ល។

**ប្រការ ១៨ :**

- សហគមន៍ជិតខាងដែលកំពុងប្រើប្រាស់ដីក្នុងដែនសហគមន៍ល្បឺនក្រែន (មានបណ្ណ័ ឬ គ្មានបណ្ណ័កម្មសិទ្ធិ) ត្រូវចូលរួមគោរព អនុវត្តទៅតាមលក្ខន្តិកៈគ្រប់គ្រងធនធានធម្មជាតិ និងផែនការគ្រប់គ្រងធនធានធម្មជាតិ តាមតំបន់ប្រើប្រាស់និមួយៗដូចជាៈ តំបន់ការពារ(ព្រៃអារក្ស ព្រៃជុំវិញភូមិ ព្រៃប្រភពទឹក ព្រៃកប់ខ្មោច ព្រៃឫស្សីការពារ) និងតំបន់ដីប្រើប្រាស់ច្រើនយ៉ាង (ទួលក្រែន ទួលកាជូច សំរាប់ចំការវិលជុំ) និងដីចាប់ពីទួលភ្នំហូចរហូតដល់ផ្លូវលេខ៧៨សំរាប់ដាំដំណាំហូបផ្លែចំរុះ។

## ជំពូក ៦

### ការហាមឃាត់

**ប្រការ ១៩ :**

- ការពង្រីកចំការ ការរានដីធ្វើជាកម្មសិទ្ធិ នៅក្នុងតំបន់ការពារត្រូវហាមឃាត់។
- ការរានដីធ្វើជាកម្មសិទ្ធិ ការលក់ ទិញ ដូរ ខ្ចី ជួល បញ្ចាំដី ដោយគ្មានការពិគ្រោះយល់ព្រម ឬ ដឹងឮពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ និងគ្មានលិខិតអនុញ្ញាតិពីអាជ្ញាធរដែនដី ស្ថាប័នជំនាញត្រូវហាមឃាត់។

**ប្រការ ២០ :**

- ហាមការនេសាទត្រីដោយប្រើ អាវុធ ជាតិផ្ទុះ ថ្នាំគីមីពុល ឧបករណ៍ឆក់ និងយ៉ាងព្រួលកាត់អូរ នៅពេលរដូវត្រីធ្វើបំលាស់ទី(រដូវវស្សា)។

ប្រការ ២១ :

- ហាមការធ្វើអាជីវកម្មគ្រប់ប្រភេទលើតំបន់គ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ដោយគ្មានការពិគ្រោះយោបល់ យល់ព្រម ពីគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិ និងគ្មានលិខិតអនុញ្ញាតិដែលចេញដោយស្ថាប័នជំនាញ អាជ្ញាធរដែនដី។

ប្រការ ២២ :

- ហាមកាប់ចំការ ឬ ប្រើប្រាស់ភ្លើងនៅក្នុងតំបន់ព្រៃការពារ និងព្រៃឬស្សី។

ប្រការ ២៣ :

- ចំពោះសហគមន៍ និងសហគមន៍ជិតខាងដែលមានចំការនៅក្បែរព្រៃការពារ ព្រៃឬស្សី ត្រូវគោរពលក្ខន្តិកៈ និងជួយការពារភ្លើងនៅពេលដុតព្រៃដើម្បីធ្វើចំការ បើសិនមានករណីចំាបាច់ត្រូវរាយការណ៍មកគណៈកម្មការ គ្រប់គ្រងធនធានធម្មជាតិភូមិដើម្បីស្នើសុំកំលាំងជួយការពារអោយបានមុន ១ថ្ងៃ។

## ជំពូក ៧

## ការផាកពិន័យ និងទណ្ឌកម្ម

ប្រការ ២៤ :

- ជនប្រព្រឹត្តបទល្មើសខុសពីលក្ខន្តិកៈខាងលើ គណៈកម្មការត្រូវធ្វើការអប់រំ ឬ ព្រមានជាលើកដំបូង ក្នុងករណីបន្ទាប់បន្សំ។ប៉ុន្តែបើការខូចខាតមានលក្ខណៈធ្ងន់ធ្ងរ គណៈកម្មការនឹងធ្វើការផាកពិន័យទៅតាម លក្ខណៈប្រព៉ៃណី ឬ ឃាត់វត្ថុតាងរាយការណ៍ជូនអាជ្ញាធរដែនដី ស្ថាប័នជំនាញ និងធ្វើពាក្យបណ្តឹង មកតុលាការដើម្បីដោះស្រាយតាមផ្លូវច្បាប់។

- ករណីមិនរៀងចាល គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិភូមិនឹងធ្វើការពិន័យទ្វេរមួយជាពីរ ប្រសិនបើជនល្មើសមិនគោរព ឬ នៅតែបន្តសកម្មភាព គណៈកម្មការរាយការណ៍ជូនអាជ្ញាធរដែនដី និងស្ថាប័នជំនាញ រួចធ្វើពាក្យបណ្តឹងមកតុលាការដើម្បីដោះស្រាយតាមផ្លូវច្បាប់។

## ជំពូក ៨

## អវសាននៃលក្ខន្តិកៈ

**ប្រការ ២៥:**

- គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន ត្រូវទទួលខុសត្រូវអនុវត្ត និងផ្សព្វផ្សាយនូវលក្ខន្តិកៈខាងលើ។

**ប្រការ ២៦:**

- លក្ខន្តិកៈខាងលើនេះមានប្រសិទ្ធិភាពទៅលើគ្រប់ប្រជាពលរដ្ឋដែលចូលទៅក្នុងដែនគ្រប់គ្រងធនធានធម្មជាតិល្បឺនក្រែន គឺមិនត្រឹមតែប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិល្បឺនក្រែនប៉ុណ្ណោះទេ។

**ប្រការ ២៧ :**

- លក្ខន្តិកៈនេះនឹងអាចធ្វើការកែសំរួលបាន ប្រសិនបើមានករណីចាំបាច់ និងដោយមានការស្នើសុំពីសហគមន៍ ឬ អ្នកដែលជាប់ពាក់ពន្ធ័នៅពេលដែលជួបប្រទះការលំបាកក្នុងពេលអនុវត្ត ។ រាល់ការកែសំរួលលក្ខន្តិកៈខាងលើនេះ ត្រូវមានសមាសភាពចូលរួមពីគ្រប់ភាគីទាំងអស់ដែលបានចុះហត្ថលេខា។

**ប្រការ ២៨ :**

លក្ខន្តិកៈខាងលើនេះចាប់អនុវត្ត និងមានប្រសិទ្ធិភាពពីថ្ងៃប្រកាសអោយប្រើប្រាស់តទៅ។